**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ..៩៣២..០៩៨.១..ប.ស្ថ

# សេចក្តីជូនដំណឹង

## ស្តីពី ការហាមឃាត់ការឈូសឆាយ កាប់ឆ្ការ ដុត រុករាន ទន្ទ្រាន កាន់កាប់ដីព្រៃ ធ្វើជាកម្មសិទ្ធិ ការទិញ-លក់ដីរដ្ឋ និងការបញ្ជាក់ការទិញ-លក់ដីរដ្ឋខុសច្បាប់ នៅក្នុងតំបន់ការពារធម្មជាតិ

ក្រសួងបរិស្ថាន សង្កេតឃើញថា បទល្មើសការឈូសឆាយ កាប់ឆ្ការ ដុត រុករាន ទន្ទ្រាន កាន់កាប់ដីព្រៃធ្វើជាកម្មសិទ្ធិ ការទិញ-លក់ដីរដ្ឋ និងការបញ្ជាក់ការទិញ-លក់ដីរដ្ឋខុសច្បាប់ នៅបន្តកើតមានឡើងនៅក្នុងតំបន់ការពារធម្មជាតិ ជាពិសេសនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ«រាម» ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ» តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ ដែនជម្រកសត្វព្រៃលំផាត់ និងដែនជម្រកសត្វព្រៃស្រែពក។ ក្នុងនោះផងដែរ មានបុគ្គលមួយចំនួនបានយកឯកសារពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ដែលរាជរដ្ឋាភិបាលបានប្រកាសជាមោឃៈរួចហើយមកធ្វើជាលេស ដើម្បីធ្វើសកម្មភាពឈូសឆាយ កាប់ឆ្ការ ដុត រុករាន ទន្ទ្រានដីព្រៃ នៅក្នុងតំបន់ការពារធម្មជាតិទាំងនេះ និងនៅលើទីតាំងដីស្របច្បាប់របស់ក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ ដែលរាជរដ្ឋាភិបាលបានផ្តល់ការអនុញ្ញាតជាគោលការណ៍។

ក្នុងន័យនេះ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសិទ្ធិស្របច្បាប់របស់ក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ ក្រសួងបរិស្ថានសូមដាក់ចេញនូវវិធានការ និងការណែនាំ ដូចខាងក្រោម៖

- ត្រូវបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពខុសច្បាប់ ជាអាទិ៍ ការឈូសឆាយ កាប់ឆ្ការ ដុត រុករាន ទន្ទ្រានដីព្រៃ ការសាងសង់ខ្ទម-រោង ការដាំដុះដំណាំ និងការអាស្រ័យផលលើដីរបស់រដ្ឋនៅក្នុងតំបន់ការពារធម្មជាតិ។
- ត្រូវបញ្ឈប់ជាបន្ទាន់ នូវរាល់ការទិញ-លក់ដីរដ្ឋ និងការបញ្ជាក់ការទិញ-លក់ដីរដ្ឋដោយខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ។

ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ នឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់បំផុត ដើម្បីទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពល្មើស ដូចបានរៀបរាប់ខាងលើ ដោយផ្អែកលើនីតិវិធីច្បាប់ជាធរមាន។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមក្រសួង ស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ជួយធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនការយល់ដឹង និងចូលរួមគោរពច្បាប់ទាំងអស់គ្នា ដោយមិនប្រព្រឹត្តិសកម្មភាពល្មើសគ្រប់រូបភាព នៅក្នុងតំបន់ការពារធម្មជាតិ ហើយសូមផ្តល់កិច្ចសហការក្នុងការអនុវត្តវិធានការចាំបាច់នានា ដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ ៕

ថ្ងៃពុធ ៣កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៨

អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006